MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# Catch and Culture

## ការអភិវឌ្ឍន៍ និងការសិក្សាស្រាវជ្រាវវិស័យជលផលនៅក្នុងតំបន់ទន្លេមេគង្គ

ភាគទី ១០ លេខ ១-២ ISSN 0859-290X ខែ មេសា ឆ្នាំ ២០០៥





## សារៈសំខាន់នៃចំណុចនីមួយៗ

- ទឹកហូរតិច តម្លៃត្រីខ្ពស់
- ទិសដៅអភិវឌ្ឍន៍ដាយត្រីអាជីវកម្មរបស់ប្រជាជនកម្ពុជា
- គំរូសំណាកកូនត្រី
- សារៈសំខាន់ព្រុយរបស់ត្រី
- ត្រីខ្ទឹង(ត្រីអន្ទង់) និងការព្រលែងចូលទៅក្នុងទន្លេ ម៉ុន
- ការបរិភោគត្រីដែលបណ្តាលឱ្យស្លាប់នៅក្នុងពិធីបុណ្យ
- ការប្រមូលផលវិលជុំបណ្តាក់
- ការផ្លាស់ប្តូរការងារមន្ត្រីនៅគណៈកម្មការទន្លេមេគង្គ

លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គបានបោះពុម្ពកំរងសៀវភៅ "*ការចិញ្ចឹម និងការចាប់ Catch and Culture*" ចំនួនបីលើកក្នុងមួយឆ្នាំនៅក្នុងទីក្រុងភ្នំពេញប្រទេសកម្ពុជា និងបានចែកចាយទៅកាន់អ្នកជាវជាង ៦៥០ នាក់នៅជុំវិញពិភពលោក ។ ព័ត៌មានជាច្រើនស្តីអំពី "*ការចិញ្ចឹម និងការចាប់*" អាចរកបានដោយសេរីតាមរយៈវេបសាយ(Website,WWW.mrcmekong.org)ដែលមានការយល់ព្រមដោយគណៈកម្មការទន្លេមេគង្គ និងព័ត៌មានតម្លៃលើកំរងសៀវភៅនេះអាចរកបានពីមជ្ឈមណ្ឌលឯកសាររបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គតាមរយៈសំបុត្រទៅកាន់: doc.centre@mrcmekong.org ។

សប្បុរសជនដែលមានបំណងបរិចាកវិភាគទានសំរាប់ទ្រទ្រង់កំរងសៀវភៅ "*ការចិញ្ចឹម និងការចាប់*" អាចផ្ញើទៅកាន់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គតាមរយៈ mrcs@mrcmekong.org ។

© គណៈកម្មការទន្លេមេគង្គ ២០០៤





**សមាសភាពក្រុមបណ្ណាធិការជាភាសាអង់គ្លេស**

លោកបណ្ឌិត *គ្រីស បាឡូ* (Chris Barlow) : នាយកកម្មវិធីជលផលនៃគណៈកម្មការទន្លេមេគង្គ

លោកបណ្ឌិត *ង្វៀន គួកអាន* (Nguyen Quoc An) : មន្ត្រីកម្មវិធីជលផលនៃគណៈកម្មការទន្លេមេគង្គ

លោក *ខឹមតាន់ វត្ថានាថាម* (Khamtanh Vatthanatham) : មន្ត្រីកម្មវិធីជលផលនៃគណៈកម្មការទន្លេមេគង្គ និង

លោក *វីយ៉ីនី អេតឌីសុន* (Virginia Addison) : មន្ត្រីទំនាក់ទំនងលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ

**សមាសភាពក្រុមបណ្ណាធិការជាខេមរៈភាសា**

លោក *សម នៅ* អនុប្រធាននាយកដ្ឋានជលផល

លោក *ម៉ៅ សំអុន* មន្ត្រីជំនួយការថ្នាក់ដឹកនាំនាយកដ្ឋានជលផល

**អ្នកបោះពុម្ពផ្សាយ** : លោក *ភិតធី ស្តា* (Peter Starr)

**ការតាក់តែង និងរចនាគំរប** : លោក *សូ សាវ៉ាត់*

**បកប្រែដោយៈ** លោក *សេង ម៉ូហិក* មន្ត្រីកម្មវិធីជំនួយការ កម្មវិធីជលផលនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ







# សារលិខិតពីនាយកប្រតិបត្តិ (CEO)

ជលផលនៃអាងទន្លេមេគង្គខាងក្រោម ( ប្រសិនបើគ្មានបញ្ហា) គឺ ផ្តល់នូវសារៈសំខាន់ដល់ប្រជាជន ១០ លាននាក់ដែលពឹងផ្អែកទៅលើត្រីដែលជាប្រភពប្រាក់ចំណូល និងអាហារដ៏មានសារៈសំខាន់។ តាមពិតវាត្រូវបានគេប៉ាន់ស្មានថា ទិន្នផលត្រី វារីសត្វបច្ចុប្បន្ននៅក្នុងអាងទន្លេមេគង្គខាងក្រោមគឺ មានប្រមាណ ៣ លានតោន ក្នុងមួយឆ្នាំ។ នេះគឺ ជាធនធានមួយដ៏មានសារៈសំខាន់ធំក្រៃលែង ប៉ុន្តែវិស័យនេះគឺ ស្ថិតនៅក្រោមការនេសាទយ៉ាងខ្លាំង។ យើងមើលឃើញបញ្ហានេះតាមរយៈការខិតខំប្រឹងប្រែងការនេសាទដែលកំពុងតែមានការកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងអាងទន្លេដោយទូទៅជាញឹកញាប់ពួកគេបានអនុវត្តការនេសាទដោយខុសច្បាប់ ដែលត្រូវគេធ្វើការពិភាក្សានៅក្នុង *ការចាប់ និងការចិញ្ចឹម* ។ ការគ្រប់គ្រងវិស័យជលផលចាំបាច់នឹងត្រូវធ្វើឱ្យប្រសើរឡើងដើម្បីកាត់បន្ថយផលប៉ះពាល់ការនេសាទខុសច្បាប់ និងការនេសាទលើសលប់។ ការគំរាមកំហែងដោយប្រយោលផ្សេងទៀតទៅលើវិស័យជលផលដូចជា ការបាត់បង់ទីជំរក ការបញ្ឆោក់ពីគុណភាពទឹក និងការគ្រប់គ្រងទៅលើទំហំនៃសេចក្តីត្រូវការ។

នៅក្នុងពេលជំនាលគ្នានេះយើងចាំបាច់ត្រូវយល់ថា ការប្រើប្រាស់ទឹកទន្លេមេគង្គក្រៅពីវិស័យជលផលគឺ ត្រូវតែឱ្យសមស្របតាមច្បាប់។ ដូចជាបញ្ហា ការស្រោចស្រពទៅលើកសិកម្ម ការផលិតថាមពលអគ្គិសនី ការធ្វើនាវាចរ និងការផ្គត់ផ្គង់ទឹកជាលក្ខណៈឧស្សាហកម្ម និងក្នុងស្រុក។ ពីវិស័យជលផលនិងភារកិច្ចរៀងៗខ្លួនគឺ ការចាប់ដៃជាមួយដៃគូជាច្រើនមកពីវិស័យផ្សេងៗជាច្រើនសំរាប់អ្នករៀបចំវិស័យជលផល និងបញ្ហាកាបន្ធូរបន្ថយអត្តសញ្ញាណដែលនឹងធ្វើឱ្យមានសុទិដ្ឋិនិយមផលិតផលជលផលក្នុងខណៈពេលដែលការយល់ព្រមសំរាប់ផលប្រយោជន៏ការអភិវឌ្ឍន៏ដែលនឹងត្រូវគេចែករំលែកទៅតាមលទ្ធិភាពដែលអាចកើតឡើងជាច្រើន។

ប្រសិនបើយើង មានគោលបំណងចង់ដឹង និងចង់បញ្ចប់ភាពក្រីក្រនៅក្នុងតំបន់ទន្លេមេគង្គទាំងនេះ យើងត្រូវតែក្រលេកទៅមើលមធ្យោបាយជាច្រើននៃការជ្រើសរើសដែលកំពុងធ្វើឡើងនិងការប្រើប្រាស់ទឹកនៃទន្លេមេគង្គប្រកបដោយនិរន្តភាព។ ខ្ញុំដឹងថាតួនាទីរបស់គណៈកម្មការទន្លេមេគង្គជាផ្នែកមួយនៃការសំរបសំរួលច្រើនជាងការអភិវឌ្ឍន៏និងការវិនិយោគនៅក្នុងផ្នែកជាច្រើនដែលទាក់ទងទៅនិងការប្រើប្រាស់ទឹកទាំងអស់ រួមមានទាំងវិស័យជលផលផងដែរ។

ការអភិវឌ្ឍន៏ប្រភពទឹកអាងទន្លេឱ្យកាន់តែធំឡើងជាអន្តរជាតិដោយមិនមានការលំបាកនិងភាពប្រថុយប្រថាន។ ប៉ុន្តែជាមួយនឹងការសហការរួមគ្នានឹងដែលមានផលប្រយោជន៏ដោយផ្អែកទៅលើកិច្ចសហប្រតិបត្តិការជិតស្និទ្ធិរវាងផ្នែកជាច្រើន និងរវាងប្រទេសជាច្រើន យើងអាចរកមើលនៅដំណោះស្រាយដែលសង្គម និងបរិស្ថានអាចទទួលយកបានសំរាប់បញ្ហាខ្លះនៃការប្រឡងប្រណាំងដែលកំពុងតែប្រឈមមុខនឹងវិស័យជលផលផ្ទាល់ និងអាងទន្លេ។ រាល់ការអភិវឌ្ឍន៏ទាំងឡាយនេះអាចបានជាផលប្រយោជន៏រួមសំរាប់ប្រជាជនដែលរស់នៅតាមដងទន្លេមេគង្គ ជាពិសេសសំរាប់ជនក្រីក្រ។

Dr Oliver Cogels
Chief Executive Officer
Mekong River Commission

## លក្ខណៈចុះទាបនៃទឹក

ដោយ *ភិតធី ស្តា* (Peter Starr)

ស្របទៅតាមរបាយទឹកភ្លៀងធ្លាក់ទាបខុសពីធម្មតាកាលពីឆ្នាំមុន និងអំឡុងរដូវប្រាំងឆ្នាំនេះកំរិតទឹកទន្លេមេគង្គត្រូវបានគេកត់ត្រាថា មានកំរិតទាបបំផុតក្នុងអំឡុង ៤៤ ឆ្នាំចុងក្រោយនេះ។ការចាប់ត្រីបានធ្លាក់ចុះពាក់កណ្តាលនៅក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជា រួមមានទាំងបឹងទន្លេសាបដែលបានរាយការណ៍ថា ដោយអាជីវកម្មនេសាទត្រីទើបតែទទួលរងនូវការគំរាមកំហែងពីរដូវរាំងស្ងួតរបស់វាដែលបណ្តាលឱ្យតម្លៃត្រីបានឡើងយ៉ាងខ្ពស់។

អ្នកស្រី *សៀង កុំសឹង* ដែលស្ថិតនៅលើទូកដែលជាផ្ទះរបស់គាត់បានជំរាបសួរទៅកាន់អ្នកនេសាទក្មេងៗដែល កំពុងកាន់ត្រីរស់ជាច្រើន និងមានតម្លៃខ្ពស់ដែលគេចាត់ទុកថា ជាផលិតផលល្អប្រណិតនៃអាស៊ីខាងកើតផងនោះ (*Oxyeleotris marmorata*)ជាពិសេស ក្នុងចំណោមប្រជាជនចិន។ មុខរបរធ្វើអាជីវកម្មត្រីរបស់ប្រជាជនកម្ពុជាគឺ ជាមុខរបរមួយសមរម្យសំរាប់ពួកគេដូចជាវេចខ្ចប់ និងដាក់ផ្លាកសំគាល់ទៅលើឡាំងរួចហុចបន្តទៅឱ្យបុរសរៀបចំបន្តដាក់ចូលក្នុងឡាំង សំរាប់នាំទៅ ហុងកុង និង សាំងកាប៉ូ ត្រីដំរីដែលភាសាចិនហៅថា ស៊ុនគីយូ (Shunke yu)។ អ្នកស្រី ***សៀង កុំសឹង*** ដែលសព្វថ្ងៃ រស់នៅភូមិដែលមានទូកជាច្រើនរយធ្វើជាផ្ទះបណ្តែតទឹកតាមមាត់ទន្លេនៃភូមិកណ្តាលនៃទីក្រុងខេត្តកំពង់ឆ្នាំង បានសង្កេតឃើញកំរិតទឹកទន្លេទាបបំផុតក្នុងចំណោមពីមុនមកដែលគាត់បានឃើញពេលនេះ។ គាត់បានបន្តទៀតថា ឥឡូវនេះទំហំនៃការរកស៊ីរបស់គាត់បានធ្លាក់ចុះ ៥0%។ មន្ត្រីជលផលមូលដ្ឋានជាច្រើនរូបបាននិយាយអំពីបញ្ហានេះ " ខេត្តកំពង់ឆ្នាំង " ស្រដៀងគ្នាទៅនឹងតំបន់ផ្ទុកទ្រូដែលមានប្រជាជន



១.៧០០ គ្រួសារកំពុងរស់នៅក្នុងភូមិបណ្តែតទឹកមួយ ដែលលាតសន្ធឹងនៅក្បែរបឹងទន្លេសាប។ កំរិតទឹកទន្លេនៅពាក់កណ្តាលខែមីនាឆ្នាំនេះគឺ ទាបជាងពាក់កណ្តាលក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន "វាជាឆ្នាំមួយដែលមានការរាំងស្ងួតយ៉ាងខ្លាំងដែលខ្ញុំបានឃើញចាប់តាំងពីឆ្នាំ ១៩៨៧ ហើយពេលនោះយើងអាចដើរឆ្លងផ្ទះជាច្រើនបាន" ដែលបាននិយាយដោយអ្នកមានលំនៅដ្ឋានជាអចិន្ត្រៃនៅទីនោះ។ ឆ្នុកទ្រូជាកន្លែងសំខាន់ដែលមានជម្រៅទឹកជ្រៅរាល់រដូវ សំរាប់កប៉ាល់នេសាទមកពីខេត្ត ៥ នៅជុំវិញបឹងទន្លេសាប នឹងដែលមានចំនួនទូកនេសាទ ៤០០ ទូក កំពុងប្រកបរបរនេសាទជារៀងរាល់ប្រចាំថ្ងៃរបស់ពួកគេ និងការដឹកជញ្ជូនទំនិញឆ្លងកាត់ដីមានសារៈសំខាន់ផងដែរ។ មន្ត្រីជលផលបាននិយាយថា ជាធម្មតាការនេសាទមានចំនួន ៨ ខែដែលគិតចាប់តាំងពីខែ មីនា ប៉ុន្តែក្នុងរយៈពេលនោះមានចំនួនពីរខែ ដែលមានការនេសាទបន្តិចបន្តួចពីព្រោះទំហំនៃការនេសាទបានធ្លាក់ចុះ ៥០ % ពីរដូវនេសាទមុន។ ដោយសារទឹកភ្លៀងធ្លាក់តិចតួចខុសពីធម្មតាកាលពីឆ្នាំមុន និងកំរិតទឹកទន្លេនៅទាបប្រជាជនបង្អង់ក្នុងការចេញទៅនេសាទ នាំឱ្យការចាប់បានតិចតួច និងតម្លៃត្រីមានការកើនឡើងជាបន្តបន្ទាប់។ ជាមួយនឹងអត្រានៃការផ្គត់ផ្គង់ត្រីយ៉ាងខ្ពស់ ដែលមានរហូតដល់ ៩០ គ.ក្រ. ក្នុងមួយឆ្នាំនៃតំបន់ជា ពិសេសសំរាប់ការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ទំនាបលិចទឹក និងដីសន្ទរនៅក្នុងប្រទេសវៀតណាមដែលអាចទទួលរងនូវអំពើគ្រប់យ៉ាងបាន។ ទោះបីយ៉ាងណាក៏ដោយសំរាប់អ្នកដែលមានចំនូលបានបន្តិចបន្តួចពីការនេសាទដែលជាផ្នែកមួយដែលបានមកពីការទូទាត់ដោយសារតែតម្លៃត្រីកើនឡើង។ អ្នកស្រី ***សៀង កុំស៊ីង*** បាននិយាយថា តម្លៃត្រីដីរសំរាប់ទំហំមធ្យមបានកើនឡើងទ្វេរពី ៦.០០០រ (1,50$)រហូតដល់ ១៥.០០០ រ (3,75$) ក្នុងមួយគីឡូក្រាមនៅក្នុងខែមីនាដើមឆ្នាំ។ ចំពោះតម្លៃត្រីប្រភេទតូចៗដែលមានទំងន់ ២០០ក្រាម អាចលក់បានខ្ពស់ជាង៤.០០០រ/១ គ.ក្រ.គឺ មានរហូតដល់ ៦០ % និងត្រីដែលមានទំងន់ចាប់ពី ១ គ.ក្រ. ឡើងទៅអាចលក់បានខ្ពស់ជាង ៣៥.០០០រ/១ គ.ក្រ គឺ មានរហូតដល់ ៤០% ដោយឡែកចំពោះតម្លៃត្រីប្រភេទផ្សេងទៀតគឺ មានកំរិតទាបយ៉ាងខ្លាំង។ មន្ត្រីជលផលនៅឆ្នុកទ្រូបាននិយាយថា ប្រភេទត្រីកាបទន្លេតូចៗដែលអ្នកស្រុកហៅថា ត្រីរៀលគឺមានតម្លៃបានត្រឹមតែពី១០០រ- ១០០០រ(25cents)/១ គ.ក្រ. នៅក្នុងខែមីនាដើមឆ្នាំ។ ការបំលាស់ទីនៃប្រភេទត្រីតូចៗទាំងនេះគឺ ជាការផ្តល់នៅចំណែកមួយយ៉ាងសំខាន់ចំពោះប្រជាជនខ្មែរចាប់សំរាប់ធ្វើការកែឆ្នៃដូចជា ប្រហុក ផ្អក និងទឹកត្រី ជាដើម។ គេបានគណនាប្រភេទត្រីជាច្រើនប្រភេទប្រហែលជាពាក់កណ្តាលនៃការចាប់ត្រីប្រចាំឆ្នាំនៃដាយត្រីអាជីវកម្មរបស់បឹងទន្លេសាប មានទីតាំងចុងទឹកស្ថិតនៅក្បែររាជធានីភំពេញ ដែលជាចំណុចប្រសព្វនៃទន្លេមេគង្គ ការចាប់ត្រីឆ្នាំនេះគឺ មានចំនួន ៦.៩៥០តោន ទាបជាង ៤៧% ពីចំនួន ១២.៤២៧តោនកាលពីដើមឆ្នាំគឺ ទាបជាងសេចក្តីរាយការណ៍ ( មើលនៅទំព័រទី ៧ ដែលបានភ្ជាប់ជាមួយ) លោកបណ្ឌិត *គ្រិស្ត បាឡូ*(Chris Barlow) ជាអ្នកគ្រប់គ្រងកម្មវិធីជលផលរបស់គណៈកម្មការទន្លេមេគង្គបានមានការចាប់អារម្មណ៍យ៉ាងខ្លាំង ទៅលើការចាប់ត្រីដែលបានធ្លាក់ចុះក្នុងប្រទេសកម្ពុជា។ គាត់បានបន្តថា " ផលត្រីដែលចាប់បានកំពុងមានការថយចុះគួរឱ្យព្រួយបារម្ភណ៏ "។ ដែលបញ្ហានេះវាបណ្តាលមកពីមានទឹកជំនន់តូច និងរយៈពេលខ្លីកាលពីរដូវវស្សាឆ្នាំមុន និងមានការអះអាងបញ្ជាក់ជាច្រើនផងដែរ ដែលបញ្ហានេះបណ្តាលមកពីមានការជាប់ពាក់ព័ន្ធទៅនឹងការនេសាទដីលើសលប់។ ការរកត្រីបានបន្តិចបន្តួចធ្វើឱ្យតម្លៃត្រីនៅទីផ្សារមានការកើនឡើង គួរឱ្យព្រួយបារម្ភណ៏ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការរស់នៅដែលអាស្រ័យទៅលើត្រីសំរាប់ផ្គត់ផ្គង់ការរស់នៅរបស់ពួកគេនៅឯជនបទ។ " បញ្ហាសំខាន់ៗដែលបានលើកឡើងគឺ វា

ទាក់ទងជាមួយទឹកដែលហូរនៅក្នុងទន្លេ ផលិតផលត្រី និងការប្រកបមុខរបររបស់គាត់នៅឯជនបទ"។ មន្ត្រីជលផលខេត្តកំពង់ឆ្នាំងបានកត់សំគាល់ថា ប្រព័ន្ធបឹងទន្លេសាបដែលគេដឹងថា កាន់តែរីងទៅៗពីមួយឆ្នាំទៅមួយឆ្នាំដូចជា ទីជំរកព្រៃលិចទឹកដែលជាប្រភពដ៏សំបូរសំរាប់ត្រីផ្លាស់ទីមករកចំណី ។ នៅរដូវវស្សាតំបន់ព្រៃលិចទឹកសំខាន់ៗជាច្រើនរបស់បឹងទន្លេសាបអាចលាតសន្ធឹងចាប់ពី ៤ ដល់ ៦ ដងធំជាងតំបន់ក្នុងរដូវប្រាំងរបស់វា។ ដូចជានៅឆ្នាំ ២០០៣ ដែលជាឆ្នាំមានការរាំងស្ងួតខ្លាំងបានធ្វើឱ្យប៉ះពាល់ដោយផ្ទាល់ការរកចំណីសំរាប់កូនត្រី និងការពងកូនរបស់ត្រីដែលគ្រប់អាយុ។ មន្ត្រីជលផលខេត្តបាននិយាយថា ការចាប់ត្រីឆ្នាំនេះមានការប៉ះពាល់យ៉ាងខ្លាំងពីព្រោះពួកគេនៅតែអនុវត្តរំលោភច្បាប់ដូចជា ការប្រើប្រាស់ឧបករណ៍នេសាទស្បៃមុង និងឧបករណ៍ឆក់ជាដើមដែលបណ្តាលឱ្យប៉ះពាល់ដល់កូនត្រីតូចៗ និងធ្វើឱ្យរបួសដល់ត្រីធំៗ ល្មម។ មន្ត្រីជលផលនៅផ្នែកទ្រូមួយរូបបាននិយាយថា ឆ្នាំនេះប្រជាជនបានកំពុងប្រើប្រាស់ ឧបករណ៍ស្បៃម៉ុង យ៉ាងច្រើនរហូតមកដល់ពេលនេះមាន ២២ ករណីផ្សេងទៀតដែលត្រូវបានចាប់ឃាត់ខ្លួនពីបទសង្ស័យបានលួចនេសាទខុសច្បាប់នៅឆ្នាំនេះ និងបានធ្វើការដកហូតស្បៃម៉ុងប្រវែងជាង ២ គីឡូម៉ែត្រ។ ថ្មីនេះលោក *ឡែន កំបែល* (Lan Campbell) ជាអ្នកជំនាញខាងបរិស្ថាន នឹងបានរួមជាមួយគណៈកម្មការទន្លេមេគង្គ បានបដិសេធរបាយការណ៍រិះគុណលើទំនប់វារីអគ្គិសនីរបស់ប្រទេសចិនដែលបានធ្វើឱ្យកំរិតទឹកទន្លេឆ្នាំនេះចុះទាប និងបានបន្តទៀតថា កំរិតទឹកដែលបានកាត់បន្ថយគឺ វាមានទំនាក់ទំនងយ៉ាងច្បាស់ទៅ និងរបាយទឹកភ្លៀងទាបកាលពីរដូវវស្សាឆ្នាំមុន។ លោក *កំបែល* បាននិយាយថា " ប្រសិនបើយើងក្រឡេកមើលទៅលើបញ្ហានៃការចាប់ត្រីពី ខែ មិថុនា ដល់ ខែ កញ្ញាគឺ នៅពេលនោះវាបានចាប់ផ្តើមកើតមានបញ្ហារួចទៅហើយ"។ ដោយផ្អែកលើព័ត៌មានលើកមុនរបស់គណៈកម្មការទន្លេមេគង្គដែលបានកំណត់យក ១៦ កន្លែងសំរាប់ធ្វើការសិក្សា និងការចេះដឹងផ្សេងៗទៀតគឺ តួលេខជាច្រើនបានបង្ហាញយ៉ាងច្បាស់ថា ចំនួនរបាយទឹកភ្លៀងដែលបានស្ទង់ឃើញទាបខុសពីធម្មតាក្នុងអំឡុងខែមិថុនា និងខែកក្កដារួមមានទាំងខែវិច្ឆិកាកាលពីឆ្នាំមុនផង។ ចាប់តាំងពីឆ្នាំ ១៩៦០ ដែលជាឆ្នាំមួយមានការរាំងស្ងួតជាងគេចំពោះទន្លេ ប្រសិនបើតាមរបាយការណ៍ខែកក្កដាបានបង្ហាញថា របាយទឹកភ្លៀងជាមធ្យមដែលទទួលបានពីការសិក្សាទាំង ១៦ កន្លែងគឺ មានកំពស់ ២៣១ ម.ម ដែលមានកំរិតទាបជាង ២៦១ ម.ម ដែលទទួលបាននៅក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ១៩៩២។ របាយទឹកភ្លៀងរវាងពីខែ កក្កដា ដល់ខែ តុលា បានបង្ហាញឱ្យដឹងនៅលំហូរជាមធ្យមនៃទឹកទន្លេមេគង្គជារៀងរាល់ឆ្នាំ ។ ដោយឡែកនៅក្នុងទីក្រុងភ្នំពេញ គេបានស្ទង់ឃើញលំហូរទឹកជាមធ្យមប្រចាំឆ្នាំគឺមានរហូតដល់ ៧៤ % សំរាប់រយៈពេល៤ខែ។ ផ្នែកដែលជាតំបន់លិចទឹកនៃអាងទន្លេមេគង្គគឺ ខ្ពង់រាបស្ថិតនៅផ្នែកខាងជើង និងខាងកើតនៃប្រទេសឡាវ "ប្រទេសឡាវផ្នែកខាងកើតនៃប្រទេសកម្ពុជា និងភាគកណ្តាលនៃប្រទេសវៀតណាម" ដែលមានរបាយទឹកភ្លៀងធ្លាក់ជាមធ្យមពី ២ ទៅ ៣ ម៉.ក្នុងមួយឆ្នាំ។ នៅក្នុងផ្នែកខ្លះនៃតំបន់អាងបន្ទាប់បន្សំដែលជាផ្នែកកណ្តាលនៃប្រទេសឡាវគឺ ជាអ្នកផ្តល់ទឹកទន្លេយ៉ាងធំជាងគេតែមួយគត់សំរាប់ទន្លេមេគង្គ ដែលគេគណនាឃើញរហូតដល់ទៅ ២០% ដែលបានបញ្ចេញទៅឱ្យជារៀងរាល់ឆ្នាំ។ ទន្លេ សេសាន នៃប្រទេសកម្ពុជា ជាតំបន់នៃអាងបន្ទាប់បន្សំធំជាងគេទី ២ (SeSan River) ហើយផ្នែកជាច្រើនទៀត ដែលមានទំនាក់ទំនងហូរចាក់ទៅទន្លេដែលស្ថិតនៅផ្នែកខាងកើតនៃប្រទេសកម្ពុជាចំណែកឯ ភាគកណ្តាលនៃ្រទេសវៀតណាម និងផ្នែកខាងត្បូងនៃប្រទេស ឡាវ បានហូរចាក់ផ្តល់ទៅឱ្យប្រមាន១៦%។ លោក *កំបែល* បាននិយាយថា ការអង្កេតប្រចាំថ្ងៃនៅក្នុងខែមីនាឆ្នាំនេះបានបង្ហាញថា ទន្លេ

សៀង សៀន នៃប្រទេសថៃ (Chiang Saen River, Thailand) បានរងនៅឥទ្ធិពលតិចជាងភាគខាងត្បូងកំពង់ផែទន្លេ ប៉ាក់ សេ នៃប្រទេស ឡាវ (Port of Pakse, Laos)ដោយសារតែកំរិតហូរទឹកទាប។ គាត់បានឱ្យដឹងថា "ប្រសិនកំរិតទឹកទន្លេមេគង្គហូរតិចដោយសារតែមូលហេតុមកពីការទប់ទឹកសំរាប់ផ្គត់ផ្គង់ទំនប់វារីអគ្គិសនី យើងសង្ឃឹមថា នឹងបានឃើញការហូរនៃទន្លេ សៀង សៀន មានឥទ្ធិពលខ្លាំងថែមទៀតជាងការហូរចុះទៅអាងទន្លេ ដែលជាកន្លែងហូរចូលមួយពីកន្លែងហូរចូលជាច្រើនទៅកាន់ទន្លេអាចធ្វើឱ្យប្រសើរឡើងចំពោះផលប៉ះពាល់។ គណៈកម្មការទន្លេមេគង្គបានវាស់វែងនៅកំពស់ទឹកទន្លេ សៀង សៀន និងទន្លេប៉ាក់ សេ ប្រចាំថ្ងៃជាច្រើនពាន់ដងដើម្បីធ្វើការប្រៀបធៀបទៅឆ្នាំ ១៩៦០ វិញ។ គេបានរកឃើញថា នៅទន្លេ សៀង សៀន មានកំរិតទឹក ១២% ស្មើ ឬ ទាបជាងកំរិតទឹកទាបបំផុតដែលបានរាយការណ៍នៅក្នុងខែមិនាឆ្នាំនេះ ហើយទន្លេ ប៉ាក់ សេ វិញជាង ៤៤ ឆ្នាំកន្លងទៅនេះ គេបានវាស់ឃើញមានតែ ៥% គត់ដែលទាប។

លោក *កំ វែបល* បានកត់សំគាល់ថា ទំនប់វារីអគ្គិសនីដែលមាននៅប្រទេសចិនធ្វើនៅលើទន្លេមេគង្គគឺ ក្នុងគោលបំណងដើម្បីទាញយកថាមពលអគ្គិសនីនឹងមិនមានបំនង ដើម្បីបង្វែរការបង្ហូរទឹកនោះទេ។ ទំនប់វារីអគ្គិសនីដែលដើរដោយកំលាំងចរន្តទឹកហូរនេះនៅពេលដែលហូរ វាមិនធ្វើឱ្យមានការខុសប្លែកពីទន្លេធម្មជាតិទេ វាគ្រាន់តែជាសកម្មភាពឬដំណើរការទូទៅមួយសំរាប់ផ្ទុកទឹកដែលលើសនៅរដូវវស្សានិងសំរាប់ផ្គត់ផ្គង់ការបង្ហូរចេញខ្លះនៅរដូវប្រាំងដែលជារឿយៗនៅពេលដែលការហូរតាមលក្ខណៈធម្មជាតិវាមិនគ្រប់គ្រាន់សំរាប់តំរូវការធ្វើឱ្យឱណាម៉ូរិល។ គាត់បាននិយាយថា ផលប៉ះពាល់ដែលត្រូវបានគេគិតទុកជាមុនរបស់ទំនប់វារីអគ្គិសនី ម៉ាន វ៉ាន និង ដា ចៅសៀន (Man wan and Da chaoshan) នោះនឹងមិនធ្វើឱ្យរដូវប្រាំងហូរធ្លាក់ច្រើនជាងការធ្លាក់ចុះតាមធម្មជាតិរបស់វានោះទេ។



*ភិតតឺ ស្តា ដែលជាអ្នកសរសេរអំពីសេដ្ឋកិច្ច និងជាអ្នកពិនិត្យមើលអំពី ការចិញ្ចឹម និងការចាប់*





# ទិសដៅរអភិវឌ្ឍន៍ដាយត្រីអាជីវកម្មរបស់ប្រជាជនកម្ពុជា: ជំនន់ និង សម្ពាធនៃការនេសាទ

លោក *កេនហ្ស៊ី ហតត្ថល* (Kent G. Hortle)
លោក *ង៉ោ ប៉េងប៊ុន* (Ngor Pengbun)
លោក *ហែម រ៉ាឌី* និង (Hem Rady)
លោក *លាង សុផា* (Lieng Sopha)

**បើតាមរបាយការណ៍កាលពីដើមឆ្នាំនេះ ការចាប់ត្រីពីដាយនៅរដូវនេះបានចំនួន ៦.៥៥០ត. គឺចុះមកនៅត្រឹម ៤៧% ដែលជាចំនួនទាបបំផុតក្នុងប្រទេសកម្ពុជា។ បញ្ហានេះមួយផ្នែកបណ្តាលមកពីកំរិតទឹកទាប ប៉ុន្តែឥឡូវនេះរយៈពេល ៣ ឆ្នាំជាបន្តបន្ទាប់កន្លងមក ផលត្រីចាប់បានបានធ្លាក់ចុះខ្លាំងដែលវាបណ្តាលមកពីមានការកើនឡើងច្រើនការនេសាប។**

នៅក្នុងអំឡុងខែកក្កដារៀងរាល់ឆ្នាំទឹកទន្លេ សាប (TonleS-ap) បានហូរបញ្ច្រាស់ទិសនៅពេលដែលប្រព័ន្ធទឹកទន្លេមេគង្គហូរឡើងទៅចូលបឹងទន្លេសាប (Great Lake) តំបន់វាលទំនាបលិចទឹក និងតំបន់ដីសើម។ ទឹកជំនន់ទន្លេមេគង្គបាននាំយកទៅកូនត្រីតូចៗជាច្រើនលានដែលបានពងកូននៅដើមទឹកនៃទន្លេមេគង្គ និងហូរទៅចាក់តាមច្រកផ្លូវទឹកផ្សេងៗគ្រប់ទីកន្លែង។ កូនត្រីតូចៗ និងត្រីមួយចំនួនដែលបានពងកូននៅក្នុងតំបន់ទឹកលិចនោះបានស៊ីចំណី និងមានការរីកធំធាត់យ៉ាងខ្លាំងនឹងធំឡើងនៅទីនោះផងដែរ។ នៅខែ តុលា កំរិតទឹកបានចាប់ផ្តើមធ្លាក់ចូលទៅក្នុងទន្លេសាប (Tonle Sap) ហើយបន្ទាប់មកចាប់ផ្តើមហូរត្រឡប់ទៅកាន់ទន្លេមេគង្គ។ ដាយថាហេតុត្រី ត្រូវបានជំរុញឱ្យទៅតាមទឹកដែលហូរត្រឡប់ថយក្រោយធ្លាក់ចូលទៅប្រភពទឹកវិញ នឹងបន្ទាប់មកបានផ្លាស់ទីទាំងហ្វូងចូលទៅបឹងទន្លេសាប។ ហ្វូងត្រីជាច្រើនធ្វើដំណើរផ្លាស់ទីនៅក្នុងខែមករា និងកុម្ភៈ ដែលចំពេលមានសកម្មភាពនេសាទត្រីគ្រប់ប្រភេទកើតឡើងយ៉ាងច្រើនកុះករ។ ពេលនោះមានឧបករណ៍នេសាទប្រភេទធំៗដែលភាសាខ្មែរហៅថា (Dai) បានធ្វើការនេសាទយ៉ាងច្រើននៅតាមដងទន្លេសាប។ មានទីតាំងមួយកន្លែងត្រូវបានសង្ស័យថា មានការនេសាទដោយប្រើឧបករណ៍ដាក់ត្រង់ចរន្តទឹក ដែលមានលក្ខណៈស្រដៀងនឹងលូសៃ្បម៉ុង(Trawl net)។ អ្នកសិក្សាស្រាវជ្រាវជាតិបារាំងបានកំណត់អាយុនៃការប្រើប្រាស់ឧបករណ៍របស់ពួកគេឱ្យត្រឡប់ទៅរកឆ្នាំ ១៨៨៤ វិញ។ មងនីមួយៗមានទទឹងប្រវែង ២៥ម៉. និងបណ្តោយប្រវែង ១២០ ម៉. ដែលបន្ថែមតែ ២-៣ម៉.ទៀតនឹងក្លាយជាជ្រលងទន្លេ។ មងជាច្រើនគេបានដាក់តំរៀបជាជួរកាត់ទន្លេដែលមានចំនួន ៦៣ មង បានដាក់កាត់ទន្លេ ១៣ កន្លែងនៅរដូវនេសាទចុងក្រោយនេះ។ នៅក្នុងខែមករា និងកុម្ភៈគឺមានការចាប់យ៉ាងខ្លាំងនៅប្រភេទត្រីដែលសំខាន់ដូចជាត្រីរៀល (*Cirrhinussiamensis* and *C.lobatus.*) ហើយឡូត៍នេសាទនីមួយៗត្រូវដាក់ឱ្យដេញថ្លៃមានរយៈពេល ២ ឆ្នាំម្តងដែលក្នុងមួយឆ្នាំៗរដ្ឋរកចំណូលបាន ១៨២.000 USD ពីការឱ្យសិទ្ធិធ្វើអាជីវកម្មនៅក្នុងដាយ។ អ្នកសិក្សាស្រាវជ្រាវជនជាតិបារាំង (Chevey and LePoulain,1940 )បានប៉ាន់ស្មានការចាប់ត្រីប្រហែលជា ១៣.៥៦៩តោន ក្នុងឆ្នាំ ១៩៣៨-៩ និងការប៉ាន់ស្មានផ្សេងៗទៀតដោផ្អែកទៅលើគំរូដែលគេបានធ្វើការសិក្សាក្រោយៗជាបន្តបន្ទាប់ដោយ លោក *ឡៀន អេ អល* ក្នុងឆ្នាំ ១៩៩៥ (Lieng *et al.*, 1995)។ ចាប់តាំងពីឆ្នាំ ១៩៩៥-៦ ការឃ្លាំមើលយ៉ាងជិតដល់មួយត្រូវបានគេឧបត្ថមបន្តសំរាប់ស្រង់យកទិន្នន័យរយៈពេលវែងដែលបានអនុវត្តនៅក្នុងវិស័យជលផលនៃប្រទេសកម្ពុជា។ លោក *វេល ខាំ* នៅឆ្នាំ ១៩៨៥ (Welcomme,1985) បានកំណត់យ៉ាងច្បាស់ថា ទិន្នផលជលផលដែលបានមកពីទំនាបលិចទឹក